**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកណ្តាល**

លេខៈ...០៤៦...ស.ស.រ

# សេចក្តីសម្រេច

## ស្តីពី

## ការលុបឈ្មោះក្រុមហ៊ុនវ៉ាវែង អភិវឌ្ឍន៍ និងមិនអនុញ្ញាតិឱ្យក្រុមហ៊ុន សំណង់ ម៉ម សុជាតិ សេង ច័ន្ទដារ៉ា និងក្រុមហ៊ុនឌីយ៉ាម៉ង់ ចូលរួមដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ នៅខេត្តកណ្តាល

## អភិបាល នៃគណៈអភិបាលខេត្តកណ្តាល

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៦៣ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ត្រាស់បង្គាប់ ស្តីពីការតែងតាំងអភិបាល នៃគណៈអភិបាលខេត្តកណ្តាល
- យោងប្រកាសលេខ ៤២៧៤ ប្រ.ក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារ នៃការិយាល័យទាំងនោះ
- យោងសេចក្តីសម្រេចលេខៈ០០១ សសរ/គ.ជ.អ.ប ចុះថ្ងៃទី១៤ខែមករា ឆ្នាំ២០០៩ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ដែលត្រូវបានកែសម្រួលលើកទី២
- យោងសេចក្តីជូនដំណឹងលេខ០៨២ សជណ/គ.ជ.អ.ប ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការពង្រឹងការទទួលខុសត្រូវ និងភាពជាម្ចាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តកិច្ចដំណើរការកំណែទម្រង់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ
- យោងរបាយការណ៍របស់ទីចាត់ការផែនការ និងវិនិយោគខេត្ត ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧
- យោងស្មារតីអង្គប្រជុំ នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧

## <u>សម្រេច</u>

**ប្រការ១.-**

ត្រូវបានលុបលទ្ធផលការដេញថ្លៃគម្រោងមូលនិធិឃុំឆ្នាំ២០១៧ របស់ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល ដែលបានដេញថ្លៃកាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ មានចំនួន៤ក្រុមហ៊ុនចូលរួមដេញថ្លៃ ដែលបានបង្ហាញពីភាពមិនប្រក្រតីដូចខាងក្រោម ៖

១. ក្រុមហ៊ុន **សេង ច័ន្ទដារ៉ា** បានកាន់សំណើដេញថ្លៃ របស់ក្រុមហ៊ុន៣ផ្សេងគ្នា យកទៅដាក់ក្នុងប្រអប់សំបុត្រដេញថ្លៃគម្រោងមូលនិធិឃុំស្អាងភ្នំ ផ្ទុយពីចំណុច ៣.៥.៣ នៃសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ។

២.ក្រុមហ៊ុន **សំណង់ ម៉ម សុជាតិ** បានឃុបឃិតគ្នាបន្លំដកទម្រង់ទី៣៩ចេញ (សេចក្តីប្រកាសស្តីពីក្រមសីលធម៌ការមិនក្លែងបន្លំ និងការមិនប្រព្រឹត្តអំពើពុករលួយ) ដើម្បីធ្វើឲ្យសំណើដេញថ្លៃរបស់ខ្លួនទាប ពុំមានសុពលភាព ។

៣.ក្រុមហ៊ុន**ឌីយ៉ាម៉ង់** និងក្រុមហ៊ុន **វ៉ាវែង អភិវឌ្ឍន៍** បានឃុបឃិតគ្នាបណ្តោយឲ្យក្រុមហ៊ុន **សេង ច័ន្ទដារ៉ា** យកសំណើដេញថ្លៃរបស់ខ្លួនទៅដាក់ក្នុងប្រអប់ដេញថ្លៃជំនួសខ្លួន និងមានតម្លៃប្រហាក់ប្រហែលគ្នា ។

**ប្រការ២.-**

ត្រូវបានលុបឈ្មោះលោក **ឡូន ខាន់រ៉ា** ប្រធានក្រុមហ៊ុន **រ៉ាវែង អភិវឌ្ឍន៍** ចេញពីបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧ របស់រដ្ឋបាលខេត្តកណ្តាល ។

**ប្រការ៣.-**

មិនអនុញ្ញាតឱ្យ លោក **ម៉ម សុជាតិ** ប្រធានក្រុមហ៊ុន **សំណង់ ម៉ម សុជាតិ** ដែលមានក្នុងបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧ លេខរៀងទី១៧ ខេត្តកំពង់ស្ពឺ ចូលរួមដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ នៅខេត្តកណ្តាល ដោយផ្ទាល់ ប្រយោល ឬ ជាតំណាងឱ្យក្រុមហ៊ុនផ្សេងៗទៀតបានឡើយ ។

**ប្រការ៤.-**

មិនអនុញ្ញាតឱ្យ លោកស្រី **សេង ច័ន្ទដាវី** ប្រធានក្រុមហ៊ុន **សេង ច័ន្ទដាវី** ដែលមានក្នុងបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧ លេខរៀងទី២៣ ខេត្តកំពង់ចាម ចូលរួមដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ នៅខេត្តកណ្តាល ដោយផ្ទាល់ ប្រយោល ឬ ជាតំណាងឱ្យក្រុមហ៊ុនផ្សេងៗទៀតបានឡើយ ។

**ប្រការ៥.-**

មិនអនុញ្ញាតឱ្យ លោក **ណូច ជូ** ប្រធានក្រុមហ៊ុន **ឌីយ៉ាម៉ង់** ដែលមានក្នុងបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧ លេខរៀងទី៧ ខេត្តស្ទឹងត្រែង ចូលរួមដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ នៅខេត្តកណ្តាល ដោយផ្ទាល់ ប្រយោល ឬ ជាតំណាងឱ្យក្រុមហ៊ុនផ្សេងៗទៀតបានឡើយ ។

**ប្រការ៦.-**

នាយករដ្ឋបាលសាលាខេត្ត នាយកទីចាត់ការផែនការនិងវិនិយោគសាលាខេត្ត ក្រុមប្រឹក្សាឃុំ សង្កាត់ ទាំង ១២៧ឃុំ សង្កាត់ ក្នុងខេត្តកណ្តាល អ្នកពាក់ព័ន្ធ លោក **ឡូន ខាន់រ៉ា** ប្រធានក្រុមហ៊ុន **រ៉ាវែង អភិវឌ្ឍន៍** លោក **ម៉ម សុជាតិ** ប្រធានក្រុមហ៊ុន **សំណង់ ម៉ម សុជាតិ** លោកស្រី **សេង ច័ន្ទដាវី** ប្រធានក្រុមហ៊ុន **សេង ច័ន្ទដាវី** និងលោក **ណូច ជូ** ប្រធានក្រុមហ៊ុន **ឌីយ៉ាម៉ង់** ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

កណ្តាល, ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១៧

**អភិបាលខេត្ត**

ម៉ៅ ភិរុណ

**ចម្លងជូន ៖**

-លេខាធិការដ្ឋាន គ.ជ.អ.ប

"ដើម្បីគោរពជូនជ្រាប"

-រដ្ឋបាលខេត្តកំពង់ស្ពឺ

-រដ្ឋបាលខេត្តកំពង់ចាម

-រដ្ឋបាលខេត្តស្ទឹងត្រែង

-ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត

"ដើម្បីជូនជ្រាប "

-ដូចក្នុងប្រការ៦ " ដើម្បីអនុវត្ត "

-ឯកសារ-កាលប្បវត្តិ